សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## កិច្ចការស្រាវជ្រាវ

# អានុភាពនៃការលុបចោល អាពាហ៍ពិពាហ៍

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **នុត វណ្ណះ**

សាស្ត្រាចារ្យណែនាំ

លោក **រុន ពណ្ណារិទ្ធិ**

ថ្នាក់ **បរិញ្ញាបត្រជាន់ខ្ពស់ នីតិសាស្ត្រ**

ជំនាញ **នីតិឯកជន** ជំនាន់ទី១០

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេរកិច្ចការស្រាវជ្រាវ ២០១៤

**រក្សាសិទ្ធិដោយ** Khmer Famous

# មាតិកា

**សេចក្តីផ្តើម** 1

១.១ អនុភាពចំពោះទ្រព្យសម្បត្តិ 2

ក/ ភាគីដែលមិនបានដឹងពីមូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍ 3

ខ/ ភាគីដែលបានដឹងពីមូលហេតុនៃការលុបចោលនៅពេលរៀបអាពាហ៍ពិពាហ៍ 3

១.២ អានុភាពចំពោះកូន 4

**សេចក្តីសន្និដ្ឋាន** 5

**ឯកសារយោង:** 6

# សេចក្តីផ្តើម

មនុស្សគ្រប់រូបតែងតែប្រាថ្នាចង់បាននូវសេចក្តីសុខ ភាពរីករាយ និងសុភមង្គល តាមរយៈការបង្កើតនូវគ្រួសារដ៏កក់ក្តៅមួយ នោះគឺការរៀបអាពាហ៍ពិពាហ៍។ បុរសម្នាក់ និងនារីម្នាក់ ដែលគ្រប់អាយុ ឬដល់នីតភាព អាចរៀបអាពាហ៍ពិពាហ៍បានដោយស្រប់ច្បាប់ ដែលភាគីទាំងសងខាងត្រូវមានអាយុគ្រប់ ១៨ឆ្នាំ ឬមានលក្ខខណ្ឌគ្រប់គ្រាន់ផ្សេងៗ ទៀតទៅតាមនីតវិធីដែលច្បាប់បានកំណត់។

យ៉ាងណាមិញ ការរៀបអាពាហ៍ពិពាហ៍ រវាងបុរសម្នាក់ និងនារីម្នាក់ មិនប្រាកដថាសុទ្ធតែមានសុភមង្គល និងមានភាពរីករាយនោះទេ។ បញ្ហាទាំងនេះ កើតឡើងដោយសារតែ ការរៀបអាពាហ៍ពិពាហ៍ មិនបានព្រមព្រៀងគ្នា និងគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍ពិតប្រាកដពីភាគីទាំងសងខាង (បុរស និងនារីដែលត្រូវរៀបអាពាហ៍ពិពាហ៍) ហើយអាចកើតមានឡើងដោយសារតែមានការគំរាមពីឪពុកម្តាយខាងបុរស ឬខាងនារី ឬ ដោយការឆបោករបស់ភាគីទាំងសងខាង បានធ្វើឱ្យភាគីណាម្នាក់ ធ្លាក់ក្នុងការភាន់ច្រឡំហើយយល់ព្រមរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាតែម្តង។ អំពើគំរាម និងការឆបោកនេះ គឺជាមូលហេតុដ៏ចម្បងនៃលុបចោលអាពាហ៍ពិពាហ៍។

ដូច្នេះ ទើបមានការបង្កើតនូវច្បាប់ឡើង ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់សហព័ទ្ធទាំងពីរក្រោយពីអនុភាពនៃការលុបចោលអាពាហ៍ពិពាហ៍ ចូលជាស្ថាពរ។ ហើយអនុភាពទាំងនោះ មានដូចជា៖ ការបែងចែកទ្រព្យសម្បត្តិ ការបែងចែកកូន និងការផ្តល់អាហារកិច្ចចំពោះកូន។

# អនុភាពនៃការលុបចោលអាពាហ៍ពិពាហ៍

ការលុបចោលអាពាហ៍ពិពាហ៍ មិនមានអនុភាពប្រតិសកម្ម មានន័យថា ការលុបចោលអាពាហ៍ពិពាហ៍ មានអនុភាពរំលាយអាពាហ៍ពិពាហ៍ ឆ្ពោះទៅរកថ្ងៃអនាគត គឺគិតចាប់ពីថ្ងៃដែលតុលាការ បានប្រកាសសាលក្រម លើសេចក្តីសម្រេចនៃលុបចោលអាពាហ៍ពិពាហ៍នោះចូលជាស្ថាពរ។

## ១.១ អនុភាពចំពោះទ្រព្យសម្បត្តិ

ក្នុងករណីមានការលែងលះគ្នា ទ្រព្យសម្បត្តិត្រូវបែងចែកគ្នាទៅតាមការព្រមព្រៀងនៃភាគីទាំងសងខាង។ ប្រសិនបើគ្មានការព្រមព្រៀងគ្នាពីសហព័ទ្ធទាំងសងខាងទេ សហព័ទ្ធម្នាក់ៗ ត្រូវយកតែទ្រព្យសម្បត្តិផ្ទាល់របស់ខ្លួន ដែលមានមុនរៀបអាពាហ៍ពិពាហ៍ និងទ្រព្យសម្បត្តិដែលខ្លួនបានទទួលជាមតក ជាអំណោយ ជាអច្ច័យទាន ក្នុងរយៈពេលមានចំណងអាពាហ៍ពិពាហ៍តែប៉ុណ្ណោះ។ ក្រៅពីនេះ សហព័ទ្ធម្នាក់ៗ មានសិទ្ធិទទួលបានទ្រព្យសម្បត្តិរួម ស្មើគ្នា គឺពាក់កណ្តាលម្នាក់។

ប៉ុន្តែ ករណីពិសេស បើសិនជាសហព័ទ្ធទាំងពីរ មិនអាចបែងចែកដឹងថា ទ្រព្យសម្បត្តិអ្វីខ្លះជាទ្រព្យសម្បត្តិរបស់ខ្លួនទេ។ សហព័ទ្ធទាំងសងខាង អាចស្នើសុំឱ្យតុលាការជាអ្នកសម្រេចសេចក្តីនៃការបែងចែកទ្រព្យសម្បត្តិរួមផ្សេងពីគោលការណ៍ខាងលើបាន ដោយគិតទៅដល់ផលប្រយោជន៍របស់កូន និងផលិតកម្ម។

ចំពោះការងារនៃគេហកិច្ច (ការងារផ្ទះ) ត្រូវចាត់ទុកថា មានតម្លៃស្មើគ្នានឹងការងារផលិតកម្ម (ការងារដែលធ្វើនៅខាងក្រៅ)។[1]

**ក/ ភាគីដែលមិនបានដឹងពីមូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍**

ភាគដែលមិនបានដឹងពីមូលហេតុនៃការលុបចោអាពាហ៍ពិពាហ៍ ត្រូវសងទ្រព្យសម្បត្តិដែលទទួលបានដោយការរៀបអាពាហ៍ពិពាហ៍ ត្រឹមកម្រិតផលប្រយោជន៍ដែលខ្លួនបានទទួល។[2] ទ្រព្យសម្បត្តិដែលបានទទួលដោយការរៀបអាពាហ៍ពិពាហ៍ទាំងនោះ រួមមាន ដូចជា:

- ទ្រព្យសម្បត្តិដែលទទួលបានដោយប្រទានកម្ម នៅពេលរៀបអាពាហ៍ពិពាហ៍ ឬក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍។
- ទ្រព្យសម្បត្តិដែលទទួលបានតាមរយ:សន្តតិកម្ម (មរតក) ឬអច្ច័យទាន (ទ្រព្យសម្បត្តិទទួលបានតាមរយ:មតកសាសន៍ = បណ្តាំមរតក) ឬ ផលប្រយោជន៍ពីការធានារ៉ាប់រងជីវិត។ល។[3]

**ខ/ ភាគីដែលបានដឹងពីមូលហេតុនៃការលុបចោលនៅពេលរៀបអាពាហ៍ពិពាហ៍**

ភាគីដែលបានដឹងពីមូលហេតុ នៃការលុបចោលនៅពេលរៀបអាពាហ៍ពិពាហ៍ ត្រូវសងផលប្រយោជន៍ទាំងអស់ ដែលទទួលបានដោយការរៀបអាពាហ៍ពិពាហ៍។ ប្រសិនបើ ភាគី

[1] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ ១៩៨៩, មាត្រា ៦៩ ដល់មាត្រា ៧០។

[2] ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០២, មាត្រា ៩៦៤, កថាខណ្ឌទី២, ទំព័រ ៣៨៦។

[3] សៀវភៅនីតិគ្រួសារ, ទំព័រ ១៣, និពន្ធដោយ: លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្ត្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត។

ម្ខាងទៀតសុចរិត ត្រូវទទួលខុសត្រូវចំពោះសំណងនៃការខូចខាតនោះ។ [4] ផលប្រយោជន៍ដែលទទួលបានដោយការរៀបអាពាហ៍ពិពាហ៍រួមមាន:

- ទ្រព្យសម្បត្តិដែលទទួលបានដោយប្រទានកម្មនៅពេលរៀបអាពាហ៍ពិពាហ៍ ឬ ក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍។
- ទ្រព្យសម្បត្តិដែលទទួលបានតាមរយៈសន្តតិកម្ម (មរតក) ឬ អច្ច័យទាន (ទ្រព្យសម្បត្តិទទួលបានតាមរយៈមតកសាសន៍ = បណ្តាំមរតក) ឬផលប្រយោជន៍ពីការធានារ៉ាប់រង ជីវិត។ល។
- រួមទាំងថ្លៃស្នាក់នៅ ថ្លៃចំណាយលើម្ហូបអាហារ និងថ្លៃកម្សាន្ត ជាដើម។[5]

## ១.២ អានុភាពចំពោះកូន

កូនដែលកើតពីភាគីនៃអាពាហ៍ពិពាហ៍ដែលអាចលុបចោលបាន ត្រូវសន្មតថាមានគតិក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ (ជាកូនរបស់បុរសជាប្តីនៃម្តាយ) ប្រសិនបើកូននោះបានកើតក្នុងអំឡុងពេល ១៨០ ថ្ងៃ គិតពីថ្ងៃរៀបអាពាហ៍ពិពាហ៍ ឬក្នុងអំឡុងពេល ៣០០ ថ្ងៃ គិតចាប់ពីថ្ងៃដែលបានរំលាយ ឬលុបចោលអាពាហ៍ពិពាហ៍។[6]

[4] ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧, មាត្រា ៩៦៩, កថាខណ្ឌទី៣, ទំព័រ ៣៩៦។

[5] សៀវភៅនីតិគ្រួសារ, ទំព័រ ១៩, និពន្ធដោយ: លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត។

[6] សៀវភៅនីតិគ្រួសារ, ទំព័រ ១១, និពន្ធដោយ: លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត។

# សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមក អានុភាពនៃការលុបចោលអាពាហ៍ពិពាហ៍ គឺមានសារសំខាន់ណាស់សម្រាប់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ជាពិសេសសម្រាប់បុគ្គលគ្រប់រូប ដែលមានបំណងបង្កើតក្រុមគ្រួសារដ៏កក់ក្តៅមួយ និងចង់បាននូវសេចក្តីសុខសប្បាយ ភាពរីករាយ និងសុភមង្គល តាមរយៈរៀបអាពាហ៍ពិពាហ៍បាន លុះត្រាតែអាពាហ៍ពិពាហ៍នោះ កើតចេញពីការព្រមព្រៀង ស្ម័គ្រចិត្ត មិនមានការគំរាម គ្មានការឆបោស និងត្រូវតែកើតចេញពីឆន្ទៈពិតប្រាកដរបស់បុរស និងនារី ទាំងពីរនាក់ ដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ហើយបានបំពេញលក្ខខណ្ឌត្រឹមត្រូវដែលច្បាប់បានកំណត់ នោះទើបអាពាហ៍ពិពាហ៍នោះ អាចសម្រេចបាន ដោយភាពជោគជ័យ។

ផ្ទុយទៅវិញ ប្រសិនបើអាពាហ៍ពិពាហ៍នោះ កើតចេញពីការគំរាម ការឆបោស ដោយភាគីណាម្នាក់នៃភាគីទាំងសងខាង។ អាពាហ៍ពិពាហ៍ដែលកើតចេញ អំពីទង្វើដូចខាងលើនេះ នឹងត្រូវបានលុបចោលវិញ ក្នុងលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ និងក្រមរដ្ឋប្បវេណី ចូលជាធរមាន៕

# ឯកសារយោង:

- ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧
- ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩
- សៀវភៅនីតិគ្រួសារ (និពន្ធដោយ: លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត